ប្រជាកុប្បកម្ម ?

សួរថា តើហេតុអ្វីបានជាគ្មានប្រជាកុប្បកម្ម ប្រឆាំងនឹងរបបក្រុងភ្នំពេញ តាមការអំពាវនាវរបស់ សម រង្សី ? អវត្តមាននេះ នាំអោយពួកជនផ្តាច់ការ និងពួកអ្នកគាំទ្ររបស់គេ យល់ឃើញថា វិធានការគាបសង្កត់ ទុកជាមុនរបស់ ហ៊ុន សែន ទៅលើមន្ត្រី, សកម្មជន និងពួកអ្នកគាំទ្ររបស់គណបក្សសង្គ្រោះជាតិ ដែលគេទុកជាពួកឧទ្ទាមរៀបចំធ្វើរដ្ឋប្រហារ ជាវិធានការត្រឹមត្រូវប្រកបដោយប្រសិទ្ធិភាព។ តែយើងក៏សួរដែរថា ការណ៍នេះ វាជាបរាជ័យរបស់ សម រង្សី ? ត្រូវដឹងថា សម រង្សី ជា អត្តគាហ[1] ទទួលផលពីបរិបទនយោបាយអន្តរជាតិ ដែលជា ស្ថានភាពស្របនឹងសកម្មភាពសកម្ម ចេញមុខរបស់គាត់។ សកម្មភាពនោះ គេចង់ឬមិនចង់ វាប្រហែលជាមានប្រភាពកិចប្ចូ្ចនយ៉ាងណាក្តី ទៅលើវិស័យមតិអន្តរជាតិ ទើបត្រូវបាន សារព័ត៌មាន និងទូរទស្សន៍បរទេសសំខាន់ៗ គេយកមកចុះផ្សាយនៅលើពិភពលោក។ ប៉ុន្តែ របាយការណ៍របស់សហគមន៍អឺរ៉ុបក្តី អង្គការសហប្រជាជាតិក្តី ស្តីពីការរំលោភសិទ្ធិមនុស្ស ពីសំណាក់របបក្រុងភ្នំពេញ វាគឺជាលទ្ធផល នៃការងារស៊ីប អង្កេត ដោយប្រុងប្រយ័ត្ន និងឯករាជ្ស ដែលគ្មានទំនាក់ទំនងផ្ទាល់នឹងសកម្មភាពរបស់ សម រង្សី នោះឡើយ។ ជាការពិត

[1] អត្តគាហ : អ្នកដែលបានចំណេញពីអ្វីមួយ, bénéficiaire.

ដំណើរការអន្តរជាតិ និងសកម្មភាព សម រង្សី រាគ្រាន់តែដើរស្របគ្នា នៅពេលត្រឹមត្រូវតែមួយ ក្នុងគោលបំណងចម គឺ ដើម្បី ស្តារលទ្ធិប្រជាធិបតេយ្យឡើងវិញនៅកម្ពុជា នៅក្នុងគតិនៃកិច្ចព្រមព្រៀងសន្តិភាព ថ្ងៃទី២៣ តុលា ឆ្នាំ ១៩៩១។ ដូច្នេះ សកម្មភាពរបស់ សម រង្សី មិនអាចទុកជាបរាជ័យនោះទេ ព្រោះជាសកម្មភាព ដែលកំពុងបន្តដំណើរ លើផ្លូវត្រឹមត្រូវ ស្របនឹងការចង់បានរបស់ប្រជាពលរដ្ឋខ្មែរ និងសគមអន្តរជាតិ។ ជាការពិតហើយ បើសិនជាសហគមន៍អឺរ៉ុប គេទំលាក់ចោលមែនពិត នូវការអនុគ្រោះពន្ធ ហៅថា EBA អ្នកដែលទទួលរងគ្រោះផ្ទាល់ និងជាបន្ទាន់ គឺ កម្មករ-ការិនី។ តែសេចក្តីសម្រេចនោះ រាជាកំហុសផ្ទាល់របស់របបនៅក្រុងភ្នំពេញ ដ្បិតខ្លួនមិនបានឆ្លើយតមតាមតម្រូវការរបស់សហគមន៍អឺរ៉ុប។ មិនត្រឹមតែមិនឆ្លើយតប តែបែរជាទុក តាមចរិតមជ្ឈត្តក:របស់ ហ៊ុន សែន ថាតម្រូវការនោះ ជានយ:អារុធ[2] របស់ សម រង្សី យកមកវាយប្រហារខ្លួន។ ការយល់ច្រឡំបែបនេះ នាំអោយរបបក្រុងភ្នំពេញ មានប្រតិកម្មផ្ទុយនឹងផលប្រយោជន៍ផ្ទាល់ខ្លួនទៅវិញ គឺ គិតតែវាយប្រហារគប ដោយប្រើមធ្យោបាយ វិសម្ហាមាត្រ ដែលធ្វើអោយ ស្ថានភាពកាន់តែអាក្រក់ទៅ។ តែអវត្តមានប្រជាកុប្បកម្ម រាអាចទុកជាចំណុចវិជ្ជមានសំរាប់របបក្រុងភ្នំពេញ ព្រោះគេអាចឃោសនាថា សម រង្សី ជាអ្នកបរាជ័យ ក្នុង

[2] នយ:អារុធ : អារុធនយោបាយ។

គោលដៅធ្វើរដ្ឋប្រហាររំលំរបបខ្លួន តែការលើកយកមូលហេតុ
រដ្ឋប្រហារ មកចោទប្រកាន់ក្នានមូលដ្ឋានពិតប្រាកដ វានាំអោ
យមាន អនុភាព អវិជ្ជមាននោះទៅវិញ ព្រោះវាគ្នានបង្ហាញ នូវ
សុទ្ធិភាពអ្វីបន្ទិចឡើយនៅក្នុងអារម្មណ៍ប្រជាពលរដ្ឋខ្មែរ។ តែ
នយ:ជន[3]ខ្មែរទាំងឡាយសព្វថ្ងៃ ក៏កុំនាំគ្នាមើលឃើញស្រាល
អវត្តមាន នៃប្រជាកុប្បកម្មនេះ ព្រោះថា ឬក៏ ការតស៊ូ
នយោបាយជាសមូហភាព វាគ្នានៅក្នុងប្រពៃណី នៃគតិខ្មែរ,
ឬក៏ ប្រជាជនខ្មែរ មានការហត់នឿយ នៅចំពោះមុខស្ថាន
ភាពជម្លោះនយោបាយដ៏យូរអង្វែង ហើយនាំគ្នា លះបង់ចោល
ការពុះពាររបស់ខ្លួន ដើម្បីការពារសិទ្ធិខ្លួនជាពលរដ្ឋ, ឬក៏ ប្រជា
ជនខ្មែរ បន្តរស់ នៅក្រោមទម្ងន់ នៃការខ្លាច នៃអំណាចរបស់
អ្នកដឹកនាំ និងការឃ្លានក្នុងស្ថានភាពអស់សង្ឃឹម ដែលនាំ
សង្កត់ចិត្តអោយរស់នៅក្នុងសេចក្ដីលង់ខ្ជៅជានិច្ច។ តែនៅ
ក្នុងសម្ងាត់ចិត្តណាមួយក៏ដោយ គួរយើងយល់ឃើញថា នយ:
ជន ជាអ្នកប្រជាធិបតេយ្យនិយម បានធ្វើគ្រប់សកម្មភាព
នយោបាយ បន្តៗគ្នាមកតាំងតែពីឆ្នាំ ១៩៤៧[4] រាប្រហែលជា
មិនគ្រប់គ្រាន់ ឬ អត់មានតែម្តង សំរាប់បំពាក់សិទ្ធិ នៃប្រជា
ពលរដ្ឋ ឬអប់រំនយោបាយ អោយមានក្នុង ស្មារតីរបស់ប្រជានុ
រាស្ត្រខ្មែរ ឬយល់ដឹងអំពីអំណាចរបស់ខ្លួន។ លាភជ័យធំៗជា
ច្រើនដងកន្លងទៅ ដែលប្រជាជាតិខ្មែរ មិនបានដឹងពីរបៀប

---

[3] នយ:ជន : អ្នកនយោបាយ។
[4] ឆ្នាំដែលស្រុកខ្មែរមានរដ្ឋធម្មនុញ្ញជាលើកដំបូង។

ចាប់យក ដើម្បីទទួលបាន អត្ថប្រយោជន៍ពីវា គឺនៅឆ្នាំ ១៩៥៣, ឆ្នាំទទួលបានឯករាជ្យជាតិពីបារាំង, នៅឆ្នាំ ១៩៧០, ឆ្នាំដែលជនខ្មែរភាគច្រើនយល់ដឹងរួមអំពីគ្រោះថ្នាក់ជាថ្មី នៃយួនកុម្មុយនិស្ត, នៅឆ្នាំ ១៩៧៣, ឆ្នាំដែលភាគីយុទ្ធការីខ្មែរទាំងពីរ, សាធារណរដ្ឋខ្មែរ និងរណសិរ្សបង្រួបបង្រួមជាតិខ្មែរ, អាចផ្សះផ្សាគ្នាបាននៅក្នុងក្របខណ្ឌ នៃកិច្ចព្រមព្រៀងសន្តិភាព ថ្ងៃទី២៧ មករា ឆ្នាំ ១៩៧៣ រវាង អាមេរិកាំង និងយួន និងរវាងខ្មែរ និងខ្មែរ ដើម្បីរៀបចំខ្លួន ការពារជាមុននៅចំពោះមុខគ្រោះថ្នាក់សក្តានុពល នៃយួនកុម្មុយនិស្ត, នៅឆ្នាំ ១៩៩១ នៅក្នុងឥទ្ធិពលកិច្ចព្រមព្រៀងសន្តិភាព ថ្ងៃទី២៣ តុលា ក្រោមការត្រួតត្រារបស់អង្គការសហប្រជាជាតិ នៅពេលនោះ ប្រជាជាតិខ្មែរ អាចមានលទ្ធភាព ធ្វើការផ្សះផ្សាជាតិជាទម្រង់ជំដើម្បីឯករាជ្យជាតិ, សន្តិភាព, លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍ជាតិគ្រប់វិស័យ។ ប៉ុន្តែអ្វីគ្រប់យ៉ាងដែលជាអំណោយផល ត្រូវបានបរាជ័យទៅវិញ ដែលនាំអោយប្រជាជាតិ ធ្លាក់ចុះមកដល់សន្ទាភាពវិនាដកម្មសព្វថ្ងៃនេះ គឺជោគជ័យ នៃរបបផ្តាច់ការ ដែលជារបបរណបយួនកុម្មុយនិស្ត។

ទោះយ៉ាងណាក៏ដោយ ក៏វាមានការចូលរួមពីប្រជាពលរដ្ឋ នៅក្នុងជីវិតនយោបាយ តាមរយៈការបោះឆ្នោត, ប៉ុន្តែជាអកុសលការបោះឆ្នោតទាំងនោះតែងតែត្រូបាន ពួកអ្នកដឹកនាំ ឬគណបក្សកាន់អំណាច ជោគជ្រាស ដើម្បីយកឈ្នះ ដូចជាការ

ចោះឆ្នោតក្លែងក្លាយនៅឆ្នាំ ២០១៨ ជាឧទាហរណ៍ជាក់ស្តែងមួយ។ អំពើទុច្ចរិតនេះឯង រាលុបបំបាត់ការខិតខំរបស់ប្រជាពលរដ្ឋ ក្នុងការចូលរួមរបស់គាត់ នៅក្នុងជីវិតនយោបាយ ដែលនាំអោយគាត់មានការខកចិត្តអកម្ម។ នៅលើចំណុចនេះ ឯង ដែលរបបក្រុងភ្នំពេញ គេទុកជាជោគជ័យរបស់គេ ទោះបីវាជាជ័យជំនះលើប្រជាពលរដ្ឋខ្លួនឯងក៏ដោយ ព្រោះអ្វីដែលជាសារៈសំខាន់ចំពោះគេ គឺការថែរក្សាអំណាចអោយបានគង់វង់ ទោះបីគេត្រូវប្រើមធ្យោបាយបែបណាក៏ដោយ ហើយការទុកជាការឈ្នះឈ្នះរបស់គេ គឺគេអាចបោកបញ្ឆោតគណបក្សប្រឆាំងបានជានិច្ច ដែលវិតតែនាំអោយប្រជាពលរដ្ឋ មានអារម្មណ៍ហួសពីការខកចិត្តអកម្ម រហូតធ្លាក់ទៅក្នុងភាពអស់សង្ឃឹម ធ្វើអត្តឃាតតែម្តង គឺជ្រើសយកការអត់ធ្មត់ទ្រាំទ្ររស់ នៅក្នុងទុក្ខលំបាកនៅក្នុងជីវភាពរបស់ខ្លួន, ដូចយ៉ាងរបស់អ្វី ដែលខ្លួនបានទទួលក្នុងកំពស់អឬរបរមា ក៏ទុកជាការប្រសើរបានដែរ។ រស់នៅក្នុងសភាពបែបនេះ គឺធ្លាស់ជារស់ រង់ចាំសេចក្ដីស្លាប់តែប៉ុណ្ណោះ។ តើចារិតនេះ ជាផ្នត់គំនិតអរិដ្ឋមានជាប្រវត្តិសាស្ត្ររបស់ប្រជាពលរដ្ឋ ខ្មែរទេឬ ? ចម្លើយជាសុទិដ្ឋិនិយមធ្លាស់ជាថា ទេ ព្រោះប្រជាពលរដ្ឋខ្មែរ ក៏ធ្លាប់ស្គាល់ជីវិតទាបខ្ពស់ នៅក្នុងប្រវត្តិសាស្ត្រជាតិខ្លួន ដែល អាចទាញយកមកធ្វើជាមេរៀន សំរាប់ជីវិតអមត នៃប្រជាជាតិខ្មែរ។ ជាការពិតកាលណាខ្មែរ ជួបប្រទះនឹងវិនិបាតម្តងៗ ខ្មែរ តែងតែស្វែងរកដំណោះស្រាយ ដើម្បីជំនះការលំបាកនោះជានិច្ច ដែលខ្មែរតែង

ហៅដំណោះស្រាយនោះថា « សាមគ្គីភាពជាកម្លាំងសំរាប់ប្រជាជាតិ »។ តែក៏អាចមានចម្លើយជាទុទិដ្ឋិនិយមដែរថា ពិតព្រោះប្រជាជាតិខ្មែរ កាន់តែរួញទៅៗទាំងទឹកដី និងវប្បធម៌ជាតិ។ ការយក់ឃើញនេះ វាមានប្រក្យាត្រភាពរបស់វា ដែលមិនអាចប្រកែកបាន គឺថា មហានគរខ្មែរពីអតីតកាល ប្រែក្លាយជាប្រទេសដ៏តូចមួយនៅលើពិភពលោកបច្ចុប្បន្ន។ វប្បធម៌ខ្មែរកំពុងរលាយនៅចំពោះមុខការហូរចូលខ្លាំងដោយចេតនាស៊ីវិលយ[5] នៃវប្បធម៌ ចិន និង យួន ដែលមានឥទ្ធិពលអវិជ្ជមានក្តីវិជ្ជមានក្តី ជារូបភាពជាក់ច្បាស់ ក្នុងការស់នៅរបស់ខ្មែរសព្វថ្ងៃ។ កម្រាញជាប្រវត្តិសាស្ត្រ នៃវប្បធម៌ខ្មែរ នៅចំពោះមុខការហូរចូល នៃវប្បធម៌បរទេស កាន់តែខ្សោយទៅៗ ដូចជារុក្ខារុករានព្រលាន នៃអារ្យធម៌អង្គរ គ្មានអ្វីសំរាប់ការពារខ្លួន។ ដូច្នេះ ខ្ចីណភាព នៃប្រជាជាតិខ្មែរ វាមានរូបភាពដូចគ្នានឹងហយន: នៃប្រាង្គប្រសាទខ្មែរនៅសម័យក្រោយអង្គរ ដែលត្រូវបានធម្មជាតិ ដណ្តើមទីយកវិញបាននៅព្រៃរំលោង ដែលមានអ្នកខ្លះនឹកស្មានថាជា ព្រៃហ៊ីតព្រៃហោង ដែលពន្លឺព្រះអាទិត្យមិនអាចតួលចូលបាន, រល្ម៉ប្រទាក់ធ្លាក់គ្នា, រាលភ្ជក់ដែលមានខ្ទោចបិសាចរស់នៅ។

សុទិដ្ឋិនិយម និងទុទិដ្ឋិនិយមខ្មែរ ដែលបានរៀបរាប់ខាងលើនេះ ជាការពិភាក្សារបស់ខ្មែរគ្មានទីបញ្ចប់ ព្រោះវាគ្មានចម្លើយ

[5] ដោយចេតនាស៊ីវិលយ : intention civilisatrice.

ជាវិធីមានសំរាប់បញ្ឈប់អត្តឆ្គតខ្មែរ។ ពីរបបនយោបាយមួយ ទៅរបបនយោបាយមួយ វាហាក់បីដូចជាពួកអ្នកដឹកនាំ នាំគ្នាបន្តែមស្រទាប់ នៃសំណាងអាក្រក់ ដល់ខេមរ:ជាតិ ដែលនាំសង្គត់ ប្រជាពលរដ្ឋខ្មែរអោយកាន់តែថប់ដង្ហើមនៅក្នុងភាពវេទនាដើបមិនរួច ដែលខ្មែរ តែងតែយកឈ្នោះនគរខ្លួន កម្ពុជា មកនិយាយកំប្លែងលែងប្រកបដោយចិត្តជូរចត់ថា កម្ម មិនជា។ អង្គហេតុទាំងអស់នេះ តើវាមិនមែនទុកជាការបញ្ជាក់អំពីអវត្តមាន នៃប្រជាកុប្បកម្ម របស់ប្រជាពលរដ្ឋខ្មែរដូច្នោះទេឬ ? បើសិនជាខ្មែរ នាំគ្នាទម្លាក់កំហុសនេះដល់ សម រង្ស៊ី ថាជាអ្នកបោកប្រជាពលរដ្ឋខ្មែរ តែមិនបានសំរេច វាហាក់បីដូចជានាំគ្នា បំភ្លេចចោលអំពើហិង្សាទាំងឡាយ របស់របបក្រុងភ្នំពេញ ដែលគេអាចប្រដូចវាថា ហ៊ុន សែន ជាអ្នកឈ្នះ។ ពិតណាស់ហើយ គេពុំអាចទុកពួកអ្នករិះគន់ សម រង្ស៊ី ថាសុទ្ធជាអ្នកគាំទ្ររបបក្រុងភ្នំពេញ តែការតិទៀន ដែលគ្មានសំណើរនៃដំណោះស្រាយ ផ្សេងមួយទៀត នៅក្នុងបរិបទនយោបាយសព្វថ្ងៃ តើវាសមហេតុផលដែរឬទេ ? អ្វីដែលជាការបារម្ភរបស់ពួកអ្នកប្រជាធិបតេយ្យនិយម គឺស្ថិតក្នុងសំនួរថា តើបុគ្គលសម រង្ស៊ី អាចជាប្រតិករ នៃប្រជាកុប្បកម្មកើតឡើងដោយខ្លួនរបស់ប្រជាពលរដ្ឋខ្មែរដែរឬទេ ? តើប្រជាពលរដ្ឋខ្មែរ ត្រូវការមានមគ្គុទេសជាការចាំបាច់ សំរាប់ធ្វើបុគ្គលធិដ្ឋាន ក្នុងការតស៊ូរបស់ខ្លួន ដើម្បីសេរីភាព និងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ដែលមានខ្លួនឯងជាម្ចាស់ នៃអំណាច ដើម្បីសំរេចដល់

ជោគវាសនារបស់ខ្លួន ? តែត្រូវដឹងដែរថា សំនួរទាំងនេះ វាជាសំនួរ ដែលខ្មែរទូទៅ នៅតែ បន្តសួរ តែវាហាក់បីរហូតមកដល់សព្វថ្ងៃ វាគ្មានចម្លើយនៅឡើយទេ ក្រៅពីអង្គុយចាំមើលកំហុសគ្នា ទុកខ្លួនជាអ្នកបរិក្សាសុចរិតបំផុត តែបែកពួក ដែលជាអំពើបាញ់រស្មី នៃអកុសសំរាប់ប្រជាជាតិខ្មែរ។